**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងទេសចរណ៍**

**លេខ** ០០៤ សណន

ថ្ងៃ ចន្ទ ១២រោច ខែបុស្ស ឆ្នាំថោះ បញ្ចស័ក ព.ស ២៥៦៧

រាជធានីភ្នំពេញ ថ្ងៃទី០៨ ខែមករា ឆ្នាំ២០២៤

# សេចក្តីណែនាំ
## ស្តីពី
## ការពង្រឹងការប្រតិបត្តិវិជ្ជាជីវៈមគ្គុទ្ទេសក៍ទេសចរណ៍ និងអ្នកបកប្រែភាសាបន្ត

**យោង៖**- ព្រះរាជក្រមលេខ នស/រកម/០៦០៩/០០៧ ចុះថ្ងៃទី១០ ខែមិថុនា ឆ្នាំ២០០៩ ដែលប្រកាសអោយប្រើប្រាស់ច្បាប់ស្តីពីទេសចរណ៍

- អនុក្រឹត្យលេខ ១៩១ អនក្រ.បក ចុះថ្ងៃទី១៧ ខែសីហា ឆ្នាំ២០១១ ស្តីពីមគ្គុទ្ទេសក៍ទេសចរណ៍
- ប្រកាសលេខ ០៤៧ ប្រក ចុះថ្ងៃទី១៧ ខែកុម្ភៈ ឆ្នាំ២០១៤ ស្តីពីការអនុវត្តក្រមប្រតិបត្តិវិជ្ជាជីវៈមគ្គុទ្ទេសក៍ទេសចរណ៍ និងក្រមសីលធម៌វិជ្ជាជីវៈមគ្គុទ្ទេសក៍ទេសចរណ៍នៃព្រះរាជាណាចក្រកម្ពុជា។

វិស័យទេសចរណ៍កម្ពុជាបាននឹងកំពុងស្ថិតក្នុងដំណាក់កាលងើបឡើងវិញពីវិបត្តិជំងឺកូវីដ-១៩ ខណៈដែលអាជីវកម្មទេសចរណ៍បានបន្តបើកឡើងវិញស្ទើរតែទាំងស្រុងក្នុងកម្រិតប្រហាក់ប្រហែលនឹងស្ថានភាពកាលពីឆ្នាំ២០១៩ ដោយមគ្គុទ្ទេសក៍ទេសចរណ៍ជាច្រើនបានវិលត្រលប់មកបម្រើសេវាកម្មជាថ្មីឡើងវិញ។ ដើម្បីចូលរួមការពង្រឹងគុណភាពសេវាកម្មឱ្យបានល្អប្រសើរប្រកបដោយភាពទុកចិត្តនិងកក់ក្តៅសម្រាប់ទេសចរជាតិ-អន្តរជាតិ ក្រសួងទេសចរណ៍មានកិត្តិយសសូមធ្វើការណែនាំដល់លោក-**លោកស្រីជាមគ្គុទ្ទេសក៍ទេសចរណ៍ និងអ្នកបកប្រែភាសាបន្តទាំងអស់** ដូចខាងក្រោម៖

- ត្រូវអនុវត្តឱ្យបានត្រឹមត្រូវនូវក្រមប្រតិបត្តិវិជ្ជាជីវៈ និងក្រមសីលធម៌វិជ្ជាជីវៈមគ្គុទ្ទេសក៍ទេសចរណ៍ ដែលក្រសួងទេសចរណ៍បានដាក់ឱ្យអនុវត្តកន្លងមក
- ត្រូវស្លៀកពាក់ឯកសណ្ឋាន ពាក់អត្តលេខ និងពាក់អាជ្ញាបណ្ណមគ្គុទ្ទេសក៍ទេសចរណ៍ឱ្យបានត្រឹមត្រូវក្នុងពេលបំពេញភារកិច្ចរបស់ខ្លួន
- ត្រូវប្រតិបត្តិឱ្យបានត្រឹមត្រូវតាមវិជ្ជាជីវៈមគ្គុទ្ទេសក៍ទេសចរណ៍ ដោយមិនដើរតួនាទីជាការីទេសចរណ៍ ឬភ្នាក់ងារទេសចរណ៍
- ត្រូវការពារប្រយោជន៍ជាតិនិងប្រយោជន៍ទេសចរ និងចូលរួមចំណែកនៅក្នុងការថែរក្សានិងគ្រប់គ្រងធនធានធម្មជាតិ លម្អបៃតង ការពារនិងអភិរក្សមរតកវប្បធម៌ ការពារសម្បត្តិវប្បធម៌ សិល្បៈ ប្រពៃណីទំនៀមទម្លាប់របស់ប្រជាពលរដ្ឋខ្មែរក្នុងរាល់សកម្មភាពទេសចរណ៍របស់ខ្លួន
- ត្រូវផ្តល់ដល់ទេសចរនូវព័ត៌មានពិត ច្បាស់លាស់ និងទទួលខុសត្រូវដូចដែលបានសន្យា ព្រមទាំងមានវិធានការសមស្រប ដើម្បីថែទាំទ្រព្យសម្បត្តិ ការពារសន្តិសុខ និងសុវត្ថិភាពដល់ទេសចរក្នុងពេលដែលទេសចរស្ថិតក្រោមការគ្រប់គ្រងរបស់ខ្លួន


អគារលេខ៣A ផ្លូវលេខ១៦៩ សង្កាត់វាលវង់ ខណ្ឌ៧មករា រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា ទូរស័ព្ទ: +៨៥៥ ២៣ ៨៨៤ ៩៧២ ទូរសារ: +៨៥៥ ២៣ ៨៨៤ ៩៧៤ E-mail: admin@mot.gov.kh Website: www.tourismcambodia.org

- ត្រូវប្ដឹង ឬរាយការណ៍ជាបន្ទាន់ទៅនគរបាលទេសចរណ៍ អាជ្ញាធរមានសមត្ថកិច្ច ឬសមត្ថកិច្ចទេសចរណ៍ដែលនៅជិតបំផុត ក្នុងករណីដឹងឬមានការសង្ស័យថាមានការប្រព្រឹត្តបទល្មើស ការជួញដូរវត្ថុបុរាណ និងបទល្មើសបេតិកភណ្ឌ ការជួញដូរកុមារ ការធ្វើអាជីវកម្មផ្លូវភេទ ការផ្សព្វផ្សាយរូបភាពនិងសម្ភារៈអាសអាភាស ឬប្រព្រឹត្តបទល្មើសព្រហ្មទណ្ឌផ្សេងទៀត
- មិនត្រូវទាមទារកម្រៃ ឬផលប្រយោជន៍ពីអ្នកលក់ ឬពីអ្នកផ្ដល់សេវាកម្មទេសចរណ៍ផ្សេងៗ
- មិនត្រូវធ្វើសកម្មភាពដែលប៉ះពាល់ជាអវិជ្ជមានដល់គោលនយោបាយជាតិលើវិស័យទេសចរណ៍។

ការប្រតិបត្តិទាំងឡាយណាដែលខុសឆ្គងតាមក្រមប្រតិបត្តិវិជ្ជាជីវៈមគ្គុទ្ទេសក៍ទេសចរណ៍ អាចនឹងក្លាយជាកម្មវត្ថុនៃការព្រមាន ការពិន័យអន្តរការណ៍ជាប្រាក់ ឬករណីធ្ងន់ធ្ងរ អាចឈានដល់ការព្យួរជាបណ្ដោះអាសន្ន ឬដកហូតអាជ្ញាបណ្ណមគ្គុទ្ទេសក៍ទេសចរណ៍ និងបណ្ណអនុញ្ញាតអ្នកបកប្រែភាសាបន្ត។

សូម លោក-លោកស្រីជាមគ្គុទ្ទេសក៍ទេសចរណ៍ និងអ្នកបកប្រែភាសាបន្តទាំងអស់ ជ្រាប និងអនុវត្តតាមសេចក្ដីណែនាំនេះដោយស្មារតីទទួលខុសត្រូវខ្ពស់។

**ក្រសួងទេសចរណ៍**

ចម្លងជូន៖
- ទីស្ដីការគណៈរដ្ឋមន្ត្រី
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- សាលារាជធានី ខេត្ត
- មន្ទីរទេសចរណ៍រាជធានី ខេត្ត
- សមាគមឧស្សាហកម្មទេសចរណ៍
- ឯកសារ កាលប្បវត្តិ

ឯកសារនេះអាចស្វែងរកតាមរយៈពាក្យគន្លឹះបាន

This document can searchable by key term please try!

Digital Book and Document by Mr.Phou Pheakdey

Website : www.pheakdey.com

Telegram : @pdl

Telephone : 016/012 75 15 79

Not perfect but can work